**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាកលវិទ្យាល័យភូមិន្ទភ្នំពេញ**

លេខ ១៤៣៣ /សកភព.កវ
/២០២៤

# សេចក្តីជូនដំណឹង

**ស្តីពីការប្រឡងជ្រើសរើសនិស្សិតចូលរៀនថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកវិទ្យាសាស្ត្រអភិរក្សជីវចម្រុះ ជំនាន់ទី២០**
**នៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញសម្រាប់ឆ្នាំសិក្សា ២០២៤-២០២៥**

**យោង៖** ប្រកាសរបស់ក្រសួងអប់រំ យុវជន និងកីឡា លេខ១៣៥៩អយក.ប្រក ចុះថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០០៥ ស្តីពីការបើកវគ្គបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកវិទ្យាសាស្ត្រអភិរក្សជីវចម្រុះ។

សាកលវិទ្យាល័យភូមិន្ទភ្នំពេញនឹងរៀបចំការប្រឡងជ្រើសរើសនិស្សិតចំនួន៣០នាក់ ដើម្បីចូលសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកវិទ្យាសាស្ត្រអភិរក្សជីវចម្រុះជំនាន់ទី២០ សម្រាប់ឆ្នាំសិក្សា ២០២៤-២០២៥។ កម្មវិធីនេះត្រូវសិក្សាជាមួយសាស្ត្រាចារ្យខ្មែរ និងបរទេស។

**លក្ខខណ្ឌជ្រើសរើស៖**
- ត្រូវចេះភាសាអង់គ្លេសជ្រៅជ្រះ
- ត្រូវមានសញ្ញាបត្រថ្នាក់បរិញ្ញាបត្រផ្នែកវិទ្យាសាស្ត្រ ឬ សញ្ញាបត្រដែលមានតម្លៃស្មើ
- ត្រូវមានបទពិសោធន៍ការងារដែលទាក់ទងនិងផ្នែកជីវចម្រុះយ៉ាងហោចណាស់រយៈពេលមួយឆ្នាំ

**សំណុំលិខិត៖**
- ពាក្យសុំចុះឈ្មោះចូលរៀន ចំនួន ០១ច្បាប់
- សញ្ញាបត្រថ្នាក់បរិញ្ញាបត្រដែលបញ្ជាក់ពីគ្រឹះស្ថានសិក្សា ខណ្ឌ ឬស្រុក ចំនួន ០១ច្បាប់
- លិខិតបញ្ជាក់ពីបទពិសោធន៍ការងារ (សម្រាប់អ្នកដែលមានការងារធ្វើ) ចំនួន ០១ច្បាប់
- រូបថតថ្មី (ផ្ទៃពណ៌ខៀវ) ទំហំ ៤ x ៦ ថតចំពីមុខ ចំនួន ០៣សន្លឹក
- រូបថតថ្មី (ផ្ទៃពណ៌ខៀវ) ទំហំ ៣ x ៤ ថតចំពីមុខ ចំនួន ០២សន្លឹក

**ទទួលពាក្យ៖**
- ចាប់ពីថ្ងៃផ្សាយដំណឹងរហូតទៅដល់ថ្ងៃពុធ ៣រោច ខែមិគសិរ ឆ្នាំរោង ឆស័ក ព.ស ២៥៦៨ ត្រូវនឹងថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០២៤

**សម័យប្រឡង៖** ថ្ងៃសៅរ៍ ៦កើត ខែបុស្ស ឆ្នាំរោង ឆស័ក ព.ស ២៥៦៨ ត្រូវនឹងថ្ងៃទី០៤ ខែមករា ឆ្នាំ២០២៥

**វិញ្ញាសាប្រឡង៖** មានបីទម្រង់គឺ សម្ភាសន៍ អាន និងសរសេរ។ ការប្រឡងទាំងបីទម្រង់នេះនឹងត្រូវធ្វើជាភាសាអង់គ្លេស ដោយផ្តោតលើបរិបទជីវចម្រុះ អេកូឡូស៊ី និងបរិស្ថាន។

**ទីកន្លែងទទួលពាក្យ៖** បន្ទប់លេខ៤១៥ ជាន់ទី៤ អាគារ A សាកលវិទ្យាល័យភូមិន្ទភ្នំពេញ (មណ្ឌល១)

**ទូរស័ព្ទទំនាក់ទំនង៖** ០៨៨ ៤០៦ ៦៣១៨/០៦៦ ៤១៥ ២០៨ (Telegram) ឬអ៊ីម៉ែល sophakthou181035@gmail.com / ith.saveng@rupp.edu.kh.

ថ្ងៃពុធ ៣កើត ខែ មិគសិរ ឆ្នាំរោង ឆស័ក ព.ស ២៥៦៨

រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ ធ្នូ ឆ្នាំ២០២៤

**សាកលវិទ្យាធិការ**

**ជ.សាកលវិទ្យាធិការ**

**ទិតល់ វ៉ែស**